KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់
សេវាខេប៊ីប្រាសាក់ម៉ូបាល

Terms and Conditions of Using KB PRASAC Mobile

បោះពុម្ពលើកទី ៣

មាតិកា

1. សេចក្តីផ្តើម....1
2. និយមន័យនៃពាក្យគន្លឹះ....1
3. ប្រភេទមុខងារសំខាន់ៗនៃកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល....3
4. ការបើកគណនីឌីជីថល (សម្រាប់អតិថិជនថ្មីមិនទាន់មានគណនីនៅខេប៊ីប្រាសាក់)....5
5. ការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (សម្រាប់អតិថិជនមានគណនីស្រាប់)....7
6. ការបើកគណនីបញ្ញើសន្សំបន្ថែម....9
7. ការស្នើសុំប័ណ្ណខេប៊ីប្រាសាក់....10
8. ប័ណ្ណនិម្មិតវីសា (Visa Virtual Card)....10
9. ម៉ោងប្រតិបត្តិការ....10
10. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់....10
11. ទំហំកំណត់នៃប្រតិបត្តិការ និងកម្រៃសេវា....11
12. សារជូនដំណឹងស្តីពីប្រតិបត្តិការកើតឡើងក្នុងគណនី (Push Notification)....11
13. លក្ខណៈពិសេសផ្សេងៗពីប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល....11
14. ការស្នើសុំបង្ខាំង ឬ ដោះបង្ខាំងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល....11
15. ការបញ្ឈប់ការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល....12
16. សុវត្ថិភាពលើការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល....12
17. សិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជន....14
18. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់....15
19. ការកែប្រែកម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង....16
20. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម....17
21. ច្បាប់ និងការដោះស្រាយវិវាទ....17
22. ស្វ័យភាព នៃបញ្ញត្តិ....17
23. ភាសា....17

1. សេចក្តីផ្តើម

1.1. លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល តទៅហៅថា **«លក្ខខណ្ឌប្រើប្រាស់»** គឺជាកិច្ចព្រមព្រៀងរវាង **លោក-លោកស្រី** ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«ខេប៊ីប្រាសាក់»** ទាក់ទងទៅនឹងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល។

1.2. សូម លោក-លោកស្រី អាន **លក្ខខណ្ឌប្រើប្រាស់** នេះដោយប្រុងប្រយ័ត្ន មុននឹងចុច **«យល់ព្រម»** ដើម្បីបន្តចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល។

1.3. នៅពេល លោក-លោកស្រី បានចុច **«យល់ព្រម»** មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌដែលបានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់នេះ ព្រមទាំងលក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្ម របស់ខេប៊ីប្រាសាក់ ហើយ លោក-លោកស្រី យល់ព្រមទទួលខុសត្រូវលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល។

2. និយមន័យនៃពាក្យគន្លឹះ

- **ពាក្យ «លោក-លោកស្រី»** ៖ សំដៅដល់អតិថិជនជា ម្ចាស់គណនី ដែលបានចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល។
- **សេវាខេប៊ីប្រាសាក់ម៉ូបាល** ៖ គឺជាសេវាកម្មមួយ ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើការចុះឈ្មោះប្រើប្រាស់ **<u>កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល</u>** នៅលើទូរស័ព្ទដៃវៃឆ្លាត ដើម្បីធ្វើប្រតិបត្តិការលើគណនីរបស់ខ្លួនបានដោយសុវត្ថិភាព នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា (24/7) ។
- **កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល** ៖ គឺជាកម្មវិធីមួយដែលអនុញ្ញាតឱ្យអតិថិជនអាចទាញយកពី App Store/Play Store នៅលើទូរស័ព្ទដៃឆ្លាតវៃ និងអាចធ្វើការចុះឈ្មោះប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ លើគណនីបញ្ញើសន្សំរបស់ខ្លួនបានគ្រប់ពេលវេលា (24/7) និងគ្រប់ទីកន្លែង។
- **គណនី** ៖ សំដៅលើគណនីប្រាក់បញ្ញើសន្សំ និង/ឬគណនីចរន្តទាំងឡាយណាដែល លោក-លោកស្រីបានបើកជាមួយ ខេប៊ីប្រាសាក់ អាចជា៖ គណនីសន្សំ ឬ គណនីចម្រើនគ្មានកាលកំណត់ ឬ គណនីចម្រើនតាមលំដាប់ ឬ គណនីបើកប្រាក់បៀវត្ស ឬ គណនីសន្សំពាណិជ្ជករ ឬ គណនីចរន្ត ឬ គណនីចរន្តព្រីមៀម។ល។

- **គណនីឌីជីថល** Digital Account ៖ ជាគណនីប្រាក់បញ្ញើសន្សំមួយប្រភេទ ដែលអតិថិជនអាចធ្វើការបើកគណនីបានដោយខ្លួនឯង (សម្រាប់អតិថិជនថ្មី ដែលមិនទាន់មានគណនីជាមួយខេប៊ីប្រាសាក់ ឬ បើកបន្ថែមសម្រាប់អតិថិជនមានគណនីស្រាប់) និងប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានភ្លាមៗតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
- **គណនីឯកត្តជន** ៖ ជាប្រភេទគណនី សម្រាប់បើកជូនអតិថិជនជារូបវន្តបុគ្គលប្រើប្រាស់ និងធ្វើប្រតិបត្តិការសាច់ប្រាក់ទៅតាមតម្រូវការផ្ទាល់ខ្លួន។
- **គណនីឯកត្តជនផ្ទាល់ខ្លួន** ៖ ជាប្រភេទគណនីឯកត្តជន ដែលមានម្ចាស់គណនីតែម្នាក់គត់។
- **គណនីឯកត្តជនរួម** ៖ ជាប្រភេទគណនីឯកត្តជន ដែលមានសមាជិករួមគណនី (គណនី) ចាប់ពី 02នាក់ឡើងទៅ។
- **លេខកូដសម្ងាត់** (PIN) ៖ គឺជាលេខកូដសម្ងាត់ផ្ទាល់ខ្លួនចំនួន 06 ខ្ទង់ (ជាលេខសុទ្ធ) ដែលត្រូវបានកំណត់ដោយផ្ទាល់ពីលោក-លោកស្រី នៅពេលចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ លេខកូដសម្ងាត់នេះត្រូវបានប្រើដើម្បីចូលទៅប្រើប្រាស់ (Login) កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
- **លេខកូដ** OTP ៖ មានពាក្យពេញគឺ One Time Password (OTP) ដែលជាលេខកូដសម្ងាត់ចំនួន **06 ខ្ទង់** ផ្សេងមួយទៀត ដែលត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិពីប្រព័ន្ធធនាគារ និងត្រូវបានផ្ញើសារទៅកាន់លេខទូរស័ព្ទ ឬ អ៊ីម៉ែល របស់លោក-លោកស្រី ដើម្បីអនុម័តលើការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ **លេខកូដ** OTP នេះមានសុពលភាពប្រើប្រាស់បានតែមួយដង ឬ មួយប្រតិបត្តិការគត់។
- **ការស្កេនស្នាមខ្ទៅដៃ/ផ្ទៃមុខ** ៖ សំដៅដល់ប្រព័ន្ធសុវត្ថិភាពនៃការស្កេនស្នាមខ្ទៅដៃ ឬ ផ្ទៃមុខនៅលើទូរស័ព្ទចល័ត (Fingerprint / Facial Recognition) សម្រាប់បញ្ជាក់អត្តសញ្ញាណអតិថិជននៅពេលចូលប្រើទូរស័ព្ទ ឬ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បន្ថែមពីលើការប្រើប្រាស់ដោយ «**លេខកូដសម្ងាត់** (PIN)»។ លោក-លោកស្រី អាចកំណត់ការចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដោយប្រើការស្កេនស្នាមខ្ទៅដៃ/ផ្ទៃមុខ លុះត្រាតែ លោក-លោកស្រី បានកំណត់ លក្ខខណ្ឌសុវត្ថិភាពនេះសម្រាប់ការចូលទៅប្រើប្រាស់ទូរស័ព្ទចល័តរបស់ លោក-លោកស្រី ជាមុន។

- ❖ **ខេអេចឃ្យូអរកូត** (KHQR Code) (Khmer Quick Respond Code) ៖ ជាឃ្យូអរកូត ដែលតំណាងឱ្យលេខគណនីរបស់ លោក-លោកស្រី ឬ ភាគីផ្សេងទៀត ប្រើសម្រាប់ទទួលប្រាក់ ឬ ទូទាត់ថ្លៃទំនិញ/សេវាកម្ម តាមរយៈមុខងារស្កេន KHQR Code។
- ❖ **ផ្ទេរប្រាក់តាមលេខកូដសម្ងាត់** ៖ ជាប្រតិបត្តិការផ្ទេរប្រាក់ពី គណនី ទៅ លេខទូរស័ព្ទ ហើយទទួលបានលេខកូដចំនួន **06ខ្ទង់** ដើម្បីយកទៅដកប្រាក់តាមម៉ាស៊ីនអេធីអឹម ឬ ម៉ាស៊ីនដាក់ប្រាក់ ឬ ម៉ាស៊ីនឆូតកាតខេប៊ីប្រាសាក់ (មិនតម្រូវប្រើប័ណ្ណ អេធីអឹម)។
- ❖ **ផ្ទេរប្រាក់អន្តរជាតិ** ៖ ជាប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេស ទូទាំងពិភពលោក តាមរយៈ ប្រព័ន្ធ SWIFT (The Society for Worldwide Interbank Financial Telecommunication)។
- ❖ **របាយការណ៍គណនី** (Bank Statement) ៖ សំដៅលើកំណត់ត្រានៃប្រតិបត្តិការចេញ ឬ ចូលទាំងឡាយនៅក្នុងគណនី ដែលលោក-លោកស្រីអាចពិនិត្យ និងទាញយកតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
- ❖ **ករណីប្រធានសក្តិ** ៖ សំដៅលើអំពើទាំងឡាយណា ដែលកើតឡើងក្រៅពីឆន្ទៈ ដោយមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជំនះបាន ឬ ដែលមិនអនុញ្ញាតឱ្យភាគីណាមួយ ឬ ទាំងពីរអាចបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្រក្រតីបានដូចជា៖ បន្ទុះភ្នំភ្លើង ទឹកជំនន់ គ្រោះរញ្ជួយដី ព្យុះសង្ឃរា ភេរវកម្ម កុបកម្ម សង្គ្រាម។ល។

3. ប្រភេទមុខងារសំខាន់ៗនៃកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

- បើកគណនីឌីជីថល (សម្រាប់អតិថិជនថ្មីមិនទាន់មានគណនីជាមួយខេប៊ីប្រាសាក់)
- ចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាលដោយខ្លួនឯង សម្រាប់អតិថិជនមានគណនីស្រាប់ (Online Self-Registration) ដូចជា៖
  - គណនីឯកត្តជន (Single Account) ឬ
  - គណនីឯកត្តជនរួម (Joint Account) ដែលមានលក្ខខណ្ឌប្រតិបត្តិការគណនី **«ម្នាក់មានសិទ្ធិចុះហត្ថលេខា /Anyone to Sign»**
- បើកគណនីប្រាក់បញ្ញើសន្សំបន្ថែម
- ភ្ជាប់គណនី និងដកគណនីដោយខ្លួនឯង
- ផ្ទេរប្រាក់ពីគណនី ទៅកាន់ គណនី នៅខេប៊ីប្រាសាក់
- ផ្ទេរប្រាក់គណនី ទៅកាន់ គណនីធនាគារផ្សេង
- ផ្ទេរប្រាក់ពីគណនី ទៅកាន់ គណនីបាគង “Bakong Wallet” (ក្នុងគ្រឹះស្ថានតែមួយ ឬ ឆ្លងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)
- ផ្ទេរប្រាក់តាមលេខកូដសម្ងាត់ (Cash-Code)

- ផ្ទេរប្រាក់អន្តរជាតិ (International Fund Transfer)
- ទូទាត់ទំនិញ / សេវាកម្មតាមរយៈការស្កេន KHQR Code (ក្នុងគ្រឹះស្ថានតែមួយ ឬ ឆ្លងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)
- ស្កេនទូទាត់ឆ្លងដែន [ថៃឃ្យូអរកូត (PromptPay)...]
- ដកប្រាក់តាមរយៈការស្កេន QR លើម៉ាស៊ីនអេធីអឹម
- ដាក់ប្រាក់តាមរយៈការស្កេន QR លើម៉ាស៊ីនដាក់ប្រាក់
- ទូទាត់វិក្កយបត្រទឹក ភ្លើង សំរាម ថ្លៃសិក្សា អចលនទ្រព្យ ប.ស.ស. ផ្លូវល្បឿនលឿន បង់ពន្ធ។ល។
- បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ
- បើកគណនីបញ្ញើមានកាលកំណត់
- កែប្រែលក្ខខណ្ឌបន្តគណនីបញ្ញើមានកាលកំណត់ (Change Rollover Option)
- កំណត់កាលវិភាគផ្ទេរប្រាក់
- កំណត់កាលវិភាគទូទាត់វិក្កយបត្រ (Schedule Payment)
- លាក់ និងបង្ហាញគណនីដោយខ្លួនឯង
- ចែករំលែកព័ត៌មានគណនី និង Deep link សម្រាប់ផ្ទេរប្រាក់
- កែប្រែឈ្មោះគណនីនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (Rename account title)
- ដោះបង្ខាំងគណនីគ្មានប្រតិបត្តិការ (Reactivation Dormant Account)
- បង្ខាំងគណនី (Block Account)
- ផ្ទេរប្រាក់ម្តងទៀត និងផ្ទេរត្រលប់ (Repeat & Return)
- បង្កើតប័ណ្ណនិម្មិតវីសាបានដោយខ្លួនឯង (Create Visa Virtual Card) និងគ្រប់គ្រងប័ណ្ណនិម្មិតបានគ្រប់ពេល
- ពិនិត្យព័ត៌មានប័ណ្ណខេប៊ីប្រាសាក់
- ស្នើសុំប័ណ្ណខេប៊ីប្រាសាក់ថ្មី
- បើកឱ្យដំណើរការប័ណ្ណខេប៊ីប្រាសាក់ដោយខ្លួនឯង
- កំណត់លេខសម្ងាត់ប័ណ្ណខេប៊ីប្រាសាក់ ករណីភ្លេច
- បង្ខាំង ឬ ដោះបង្ខាំងប័ណ្ណខេប៊ីប្រាសាក់
- បញ្ចូល (Upload) KHQR Code របស់ខេប៊ីប្រាសាក់ ឬ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេង ដែលបានរក្សាទុក (Save) ក្នុង Photos/Gallery ដើម្បីទូទាត់ទំនិញ/សេវាកម្ម
- ពិនិត្យសមតុល្យ ឬ របាយការណ៍គណនី និងទាញយករបាយការណ៍គណនី (Account Statement and download)
- ពិនិត្យព័ត៌មានគណនីបញ្ញើមានកាលកំណត់ និងព័ត៌មានកម្ចី
- ទាញយកកាលវិភាគសងប្រាក់ (Download Loan Repayment Schedule)
- ស្នើសុំកម្ចី (Loan Against TD...)
- មុខងារ Data Sponsor របស់ក្រុមហ៊ុន Smart និង Metfone ដែលអតិថិជនអាចប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ករណីគ្មានសមតុល្យក្នុង Sim Card
- ពិនិត្យអត្រាប្តូរប្រាក់
- ប្តូរលេខកូដសម្ងាត់ (PIN) សម្រាប់ចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

- កំណត់លេខកូដសម្ងាត់ថ្មី ករណីភ្លេច
- ពិនិត្យទីតាំងម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនដាក់ប្រាក់ ទីតាំងហាងរបស់ពាណិជ្ជករ និងសាខាខេប៊ីប្រាសាក់
- បង្កើតទម្រង់ផ្ទេរប្រាក់ និង ទូទាត់វិក្កយបត្រ (Create Template) និង
- មុខងារថ្មីផ្សេងៗទៀត ដែលនឹងដាក់ឱ្យប្រើប្រាស់នាពេលអនាគត។ល។

4. ការបើកគណនីឌីជីថល (សម្រាប់អតិថិជនថ្មីមិនទាន់មានគណនីនៅខេប៊ីប្រាសាក់)

4.1. អតិថិជនអាចធ្វើការបើកគណនីឌីជីថលបានដោយខ្លួនឯង តាមរយៈ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នៅលើទូរស័ព្ទចល័តរបស់ខ្លួនបានគ្រប់ពេលវេលា (24/7) និង គ្រប់ទីកន្លែង

4.2. អតិថិជនត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

1) មានអាយុចាប់ពី 16 ឆ្នាំ ឡើងទៅ
2) ជាជនជាតិខ្មែរ
3) មានប្រើប្រាស់ទូរស័ព្ទជាលេខផ្ទាល់ខ្លួន
4) មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ដើម និងមានសុពលភាព
5) បំពេញព័ត៌មានផ្ទាល់ខ្លួន រួមមាន លេខទូរស័ព្ទ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ លេខអត្តសញ្ញាណប័ណ្ណ កាលបរិច្ឆេទផុតសុពលភាព និងអាសយដ្ឋានច្បាស់លាស់
6) ថតរូបផ្ទាល់ខ្លួន និងថតរូបអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល
7) ត្រូវយល់ព្រមគោរពតាម «លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល» នេះ។

4.3. បន្ទាប់ពីចុះឈ្មោះបើកគណនីឌីជីថលបានដោយជោគជ័យ អតិថិជននឹងទទួលបានគណនីឌីជីថលចំនួន **02 គណនី** ដោយស្វ័យប្រវត្តិ គឺ **គណនីប្រាក់រៀល** (KHR) និង **គណនីប្រាក់ដុល្លារអាមេរិក** (USD)។

4.4. អតិថិជនដែលបានចុះឈ្មោះបើកគណនីដោយខ្លួនឯងនេះត្រូវបានចាត់ថ្នាក់អតិថិជននៅក្នុងកម្រិត **«អតិថិជនថ្នាក់មធ្យម / Partial KYC»** ដែលទំហំទឹកប្រាក់បញ្ញើនៅក្នុងគណនី និងទំហំនៃការធ្វើប្រតិបត្តិការត្រូវបានកំណត់ទៅតាមលក្ខខណ្ឌនៃការប្រើប្រាស់គណនី ដូចខាងក្រោម៖

- អត្រាការប្រាក់ប្រចាំឆ្នាំ៖ ចន្លោះពី 1.50% ទៅ 4.00% យោងទៅតាមសមតុល្យគណនីជាក់ស្តែង
- ការប្រាក់ត្រូវបានបង្គរជាប្រចាំថ្ងៃ និងបញ្ចូលក្នុងគណនីអតិថិជនជាប្រចាំខែ
- អត្រាពន្ធកាត់ទុក៖ 4% លើការប្រាក់សរុបដែលទទួលបាន
- មិនតម្រូវសមតុល្យអប្បបរមាដាក់ដំបូង (Initial Deposit) និងសមតុល្យអប្បបរមាក្នុងគណនី (Minimum Deposit)
- ទំហំទឹកប្រាក់បញ្ញើអតិបរមាសម្រាប់អតិថិជនម្នាក់៖ USD 10,000 ឬ សមមូលប្រាក់រៀល
- ទំហំទឹកប្រាក់សម្រាប់ធ្វើប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ក្នុងមួយថ្ងៃ ឬ ក្នុងមួយប្រតិបត្តិការ សម្រាប់អតិថិជនម្នាក់៖ USD 3,000 ឬ KHR 12,000,000។

4.5. អតិថិជនអាចប្តូរចំណាត់ថ្នាក់ពីអតិថិជន **«អតិថិជនថ្នាក់មធ្យម / Partial KYC»** ទៅ **«អតិថិជនពេញលេញ / Full KYC»** ដោយត្រូវអញ្ជើញមកកាន់សាខាណាមួយរបស់ ខេប៊ីប្រាសាក់ ដើម្បីអនុញ្ញាតឱ្យ ខេប៊ីប្រាសាក់ ធ្វើបច្ចុប្បន្នភាព និងធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណទៅតាម «វិធាននៃការយកចិត្តទុកដាក់ស្គាល់អតិថិជន (Know Your Customer)»។

4.6. បន្ទាប់ពីអតិថិជនបានធ្វើការផ្លាស់ប្តូរទៅជា **«អតិថិជនពេញលេញ / Full KYC»** អតិថិជនអាចប្រើប្រាស់គណនីពេញលេញបាន ដោយមិនកំណត់ទំហំលើការដាក់ប្រាក់ និងអាចប្រើប្រាស់សេវា និងធ្វើប្រតិបត្តិការបានទូលំទូលាយទៅតាមលក្ខខណ្ឌ និងសេវាកម្មនីមួយៗរបស់ខេប៊ីប្រាសាក់។

4.7. សុវត្ថិភាពនៃការបើកគណនីឌីជីថល៖

- នៅក្នុងដំណើរការនៃការបើកគណនីឌីជីថលតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល អតិថិជននឹងទទួលបានលេខកូដ One-Time Password (OTP) ចំនួន 06 ខ្ទង់ ដែលប្រព័ន្ធនឹងផ្ញើចូលទៅកាន់សារទូរស័ព្ទចល័តរបស់អតិថិជន (លេខទូរស័ព្ទដែលអតិថិជនប្រើប្រាស់សម្រាប់បើកគណនីឌីជីថល) ដើម្បីអនុម័តលើការបើកគណនីនោះ
- លេខកូដ One-Time Password (OTP) នឹងត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិ (Auto Refill) គឺមិនតម្រូវឱ្យអតិថិជនធ្វើការវាយបញ្ចូលដោយខ្លួនឯងឡើយ
- ខេប៊ីប្រាសាក់នឹងផ្ញើសារជូនដំណឹងបន្ថែមទៀតទៅកាន់ទូរស័ព្ទ (SMS to Phone Number) របស់អតិថិជនដែលប្រើប្រាស់សម្រាប់ចុះឈ្មោះប្រើប្រាស់គណនីឌីជីថល បន្ទាប់ពីគណនីបើកបានជោគជ័យ
- ឯកសារបញ្ជាក់អត្តសញ្ញាណអតិថិជនត្រូវបានផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធ Cambodia Data Exchange (CamDX) ដើម្បីធានាពីសុពលភាព និងភាពពិតប្រាកដនៃឯកសារ។

4.8. ការដាក់ប្រាក់ទៅក្នុងគណនីឌីជីថល៖

- ដាក់ប្រាក់នៅតាមបញ្ជរបេឡា នៃសាខាណាមួយរបស់ ខេប៊ីប្រាសាក់
- ដាក់ប្រាក់តាមរយៈម៉ាស៊ីនដាក់ប្រាក់ របស់ខេប៊ីប្រាសាក់
- ផ្ទេរប្រាក់ចូលតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ កម្មវិធីធនាគារចល័តរបស់ធនាគារផ្សេង ឬ
- តាមរយៈមធ្យោបាយផ្សេងៗទៀតផ្តល់ដោយខេប៊ីប្រាសាក់។

4.9. ការដកប្រាក់ ឬ ការធ្វើប្រតិបត្តិការផ្សេងៗ៖

- អាចធ្វើគ្រប់ប្រភេទនៃប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល
- ករណីចង់ដកជាសាច់ប្រាក់ (Cash out) អតិថិជនអាចធ្វើប្រតិបត្តិការ ផ្ទេរប្រាក់តាមលេខកូដសម្ងាត់ (Cash-Code) ដើម្បីទទួលបានលេខកូដសម្ងាត់ចំនួន 06 ខ្ទង់ ឬ ធ្វើប្រតិបត្តិការស្កេន QR ដើម្បីធ្វើការដកប្រាក់តាមរយៈម៉ាស៊ីនអេធីអឹម ឬ ម៉ាស៊ីនដាក់ប្រាក់
- អាចធ្វើប្រតិបត្តិការតាមបញ្ជរបេឡា ឬ ប្រើប្រាស់ប័ណ្ណ លុះត្រាតែបានធ្វើបច្ចុប្បន្នភាពទៅជា «អតិថិជនពេញលេញ / Full KYC» ជាមុនសិន។

4.10. គណនីឌីជីថល ដែលមិនមានប្រតិបត្តិការលើសពី 365 ថ្ងៃ នឹងក្លាយជាគណនីគ្មានប្រតិបត្តិការ ដែលត្រូវអនុវត្តការកាត់កម្រៃសេវាជាប្រចាំខែ ទៅតាមកម្រៃដូចមានបង្ហាញនៅក្នុងវេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់។

4.11. សម្រាប់ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬ សិទ្ធិប្រើប្រាស់គណនី (បន្ថែមអ្នករួមគណនី...) ឬ បិទគណនី (Close Account) អតិថិជនត្រូវអញ្ជើញមកកាន់សាខាណាមួយរបស់ខេប៊ីប្រាសាក់ ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណច្បាប់ដើម និងមានសុពលភាពសម្រាប់ការផ្ទៀងផ្ទាត់ពី ខេប៊ីប្រាសាក់។

5. ការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (សម្រាប់អតិថិជនមានគណនីស្រាប់)

5.1. លក្ខខណ្ឌតម្រូវនៃការចុះឈ្មោះប្រើប្រាស់

ក) ជាអតិថិជនឯកត្តជន (Individual) ដែលមានអាយុចាប់ពី 16 ឆ្នាំ ឡើងទៅ

ខ) មានគណនីប្រាក់បញ្ញើសន្សំនៅខេប៊ីប្រាសាក់ (គណនីឯកត្តជនផ្ទាល់ខ្លួន (Individual Single Account) ឬ គណនីរួម ដែលមានលក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា/Anyone to Sign»)

គ) មានទូរស័ព្ទចល័តឆ្លាតវៃ (Smart Phone) ដែលប្រតិបត្តិដោយប្រព័ន្ធ iOS ឬ Android និងលេខទូរស័ព្ទប្រើប្រាស់ជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយទូរស័ព្ទ និងលេខទូរស័ព្ទនេះត្រូវនៅជាមួយគ្នា

ឃ) ត្រូវដំឡើង **កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile App)** នៅលើទូរស័ព្ទជាមួយលេខទូរស័ព្ទដែលមានសុពលភាព និងជាលេខដែលបានផ្តល់មក ខេប៊ីប្រាសាក់ ពេលស្នើសុំបើកគណនី

ង) ត្រូវបញ្ចូលព័ត៌មានចាំបាច់មួយចំនួនរួមមាន **លេខគណនី ថ្ងៃខែឆ្នាំកំណើត** និង **លេខទូរស័ព្ទ** ឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីតម្រូវនៃប្រព័ន្ធសម្រាប់ការចុះឈ្មោះប្រើប្រាស់

ច) ត្រូវកំណត់ **លេខកូដសម្ងាត់ (PIN)** ផ្ទាល់ខ្លួន ចំនួន 06 ខ្ទង់ សម្រាប់ចូលប្រើប្រាស់ (Login) កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដោយខ្លួនឯង និង/ឬ អាចកំណត់ការ**ស្កេនស្នាមខ្ចៅដៃ/ផ្ទៃមុខ (Fingerprint /Facial Recognition)** ដើម្បីបង្កើនសុវត្ថិភាពនៃការចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

ឆ) ត្រូវយល់ព្រមគោរពតាម «**លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល**» នេះ។

5.2. នៅក្នុងដំណើរការនៃការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល លោក-លោកស្រីនឹងទទួលបាន **លេខកូដ One-Time Password (OTP)** ចំនួន 06 ខ្ទង់ ដែលប្រព័ន្ធនឹងផ្ញើចូលទៅកាន់ប្រអប់សារលេខទូរស័ព្ទចល័តរបស់ លោក-លោកស្រី ដែលផ្តល់មក ខេប៊ីប្រាសាក់ ចុងក្រោយបំផុត ដើម្បីអនុម័តលើប្រតិបត្តិការនៃការស្នើសុំចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាលតាមរយៈទូរស័ព្ទចល័ត។

5.3. នៅពេលអតិថិជនបានចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាលបានជោគជ័យ នោះគណនីទាំងអស់របស់លោក-លោកស្រី រួមមានគណនីឯកត្តជនផ្ទាល់ខ្លួន (Single Account) និងគណនីរួម ដែលមានលក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា/Anyone to Sign» នឹងភ្ជាប់ដោយស្វ័យប្រវត្តិទៅក្នុង «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile)» ជាមួយកម្រិតសិទ្ធិប្រើប្រាស់គណនី «ពេញលេញ / Full Access» ដើម្បីអនុញ្ញាតឱ្យ លោក-លោកស្រី អាចធ្វើគ្រប់ប្រភេទនៃប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុបានភ្លាមៗនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

5.4. រាល់ការចូលប្រើប្រាស់ (Login) **កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល** លោក-លោកស្រី អាចប្រើលេខទូរស័ព្ទ (លេខទូរស័ព្ទចុងក្រោយបំផុតដែលផ្តល់មក ខេប៊ីប្រាសាក់) ឬ អ៊ីម៉ែល (ករណីអតិថិជនមិនមានប្រើប្រាស់លេខទូរស័ព្ទ) និង**លេខកូដសម្ងាត់ (PIN) ចំនួន 06 ខ្ទង់** ឬ **ការស្កេនស្នាមខ្មៅដៃ/ផ្ទៃមុខ (Fingerprint/Facial Recognition)** ដែលលោក-លោកស្រីបានកំណត់ដោយខ្លួនឯងនៅពេលចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

5.5. **លក្ខខណ្ឌប្រើប្រាស់គណនីភ្ជាប់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល**

5.5.1. កម្រិតសិទ្ធិប្រើប្រាស់គណនីភ្ជាប់ជាមួយកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ចែកចេញជា 02 ប្រភេទគឺ៖

- **កម្រិតសិទ្ធិ «ពេញលេញ / Full Access»**៖ ជាកម្រិតសិទ្ធិនៃការប្រើប្រាស់គណនីនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដែលអនុញ្ញាតឱ្យ លោក-លោកស្រី អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានគ្រប់មុខងារប្រតិបត្តិការដូចជា ផ្ទេរប្រាក់ ទូទាត់ ពិនិត្យព័ត៌មានគណនី ពិនិត្យព័ត៌មានកម្ចី ស្នើសុំកម្ចី ពិនិត្យអត្រាប្តូរប្រាក់ ឬ មុខងារផ្សេងៗទៀត។
- **កម្រិតសិទ្ធិ «ពិនិត្យព័ត៌មាន / View Only»**៖ ជាកម្រិតសិទ្ធិនៃការប្រើប្រាស់គណនីនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដែលអនុញ្ញាតឱ្យ លោក-លោកស្រី មានសិទ្ធិត្រឹមតែពិនិត្យព័ត៌មានគណនី ពិនិត្យព័ត៌មានកម្ចី អត្រាប្តូរប្រាក់ ឬ ព័ត៌មានផ្សេងៗ ដោយមិនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុដូចផ្ទេរប្រាក់ ឬ ទូទាត់ បានឡើយ។

5.5.2. គណនីឯកត្តជនផ្ទាល់ខ្លួន (Single Account) ឬ គណនីឯកត្តជនរួម (Joint Account) ដែលបានកំណត់លក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា / Anyone to sign» ដែលលោក-លោកស្រីបានប្រើប្រាស់ ដើម្បីធ្វើការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នឹងត្រូវបានកំណត់កម្រិតសិទ្ធិប្រើប្រាស់គណនី **«ពេញលេញ/Full Access»** ដោយស្វ័យប្រវត្តិ។

5.5.3. ករណី លោក-លោកស្រី ចង់ប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីពី **«ពេញលេញ / Full Access»** ទៅ/មក **«ពិនិត្យព័ត៌មាន / View Only»** លោក-លោកស្រី អាចស្នើសុំប្តូរបាន ជាលាយលក្ខណ៍អក្សរនៅតាមសាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតបំផុត។

5.5.4. ករណី លោក-លោកស្រី មានបំណងចង់ភ្ជាប់គណនីបន្ថែមទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នោះលោក-លោកស្រី អាចធ្វើការភ្ជាប់គណនីបន្ថែមបាន (សម្រាប់គណនីឯកត្តជនផ្ទាល់ខ្លួន ឬ គណនីឯកត្តជនរួម ដែលមានលក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា / Anyone to sign») ដោយខ្លួនឯងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដោយត្រូវអនុវត្តតាមនីតិវិធីតម្រូវពីប្រព័ន្ធ ឬ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់សាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតលោក-លោកស្រី។

5.5.5. ករណីស្នើសុំភ្ជាប់ **គណនីឯកត្តជនរួម (Joint Account)** ដែលមាន **លក្ខខណ្ឌប្រតិបត្តិការគណនីខុសពី «ម្នាក់មានសិទ្ធិចុះហត្ថលេខា / Anyone to sign»** ទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល លោក-លោកស្រីអាចស្នើសុំភ្ជាប់បានជាលាយលក្ខណ៍អក្សរនៅតាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត ដោយការស្នើសុំត្រូវយោងទៅតាម «លក្ខខណ្ឌប្រតិបត្តិការគណនី» នៃគណនីនីមួយៗដែលស្នើសុំភ្ជាប់។

5.5.6. គណនីបញ្ញើមានកាលកំណត់ (Term Deposit Account) និងគណនីសន្សំតាមផែនការ (Savings Plan Account) នឹងត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ករណី**គណនីប្រភព** ត្រូវបានភ្ជាប់ទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

5.5.7. គណនីកម្ចី (Loan Account) ត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ករណីអ្នកឈរឈ្មោះខ្ចី ឬ អ្នករួមខ្ចីបានចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដោយភ្ជាប់គណនីសន្សំសម្រាប់ទូទាត់សងកម្ចី ជាមួយកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

5.6. **លក្ខខណ្ឌដកគណនីភ្ជាប់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល**

5.6.1. លោក-លោកស្រី អាចដកគណនីដែលភ្ជាប់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានដោយខ្លួនឯងតាមរយៈទូរស័ព្ទ (សម្រាប់គណនីឯកត្តជនផ្ទាល់ខ្លួន ឬ គណនីឯកត្តជនរួម ដែលមានលក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា / Anyone to sign») ដោយត្រូវអនុវត្តតាមនីតិវិធីតម្រូវពីប្រព័ន្ធ ឬ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរនៅសាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតលោក-លោកស្រី

5.6.2. សម្រាប់ **គណនីឯកត្តជនរួម (Joint Account)** ដែលមាន **លក្ខខណ្ឌប្រតិបត្តិការគណនីខុសពី «ម្នាក់មានសិទ្ធិចុះហត្ថលេខា / Anyone to Sign»** ត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរនៅសាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតលោក-លោកស្រី។

6. ការបើកគណនីបញ្ញើសន្សំបន្ថែម

6.1. លោក-លោកស្រី អាចបើកគណនីសន្សំបន្ថែមទៀតបានតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ហើយប្រភេទគណនី ដែលអតិថិជនអាចជ្រើសរើសបើកដោយខ្លួនឯងមានដូចជា៖

- គណនីសន្សំ / Savings Account
- គណនីចម្រើនគ្មានកាលកំណត់ / Unfixed Deposit Account
- គណនីចម្រើនតាមលំដាប់ / Flexi Growth Savings Account
- គណនីឌីជីថល / Digital Account

6.2. លោក-លោកស្រី អាចជ្រើសរើសប្រភេទរូបិយប័ណ្ណនៃគណនីចំនួន ០២ គឺ៖

- ប្រាក់រៀល (KHR) និង
- ប្រាក់ដុល្លារអាមេរិក (USD)

6.3. សមតុល្យអប្បបរមាដាក់ដំបូង (Initial Deposit)៖ មិនតម្រូវ។

6.4. សមតុល្យអប្បបរមាក្នុងគណនី (Minimum Deposit)៖ តម្រូវតាមប្រភេទគណនីនីមួយៗ

6.5. ទំហំទឹកប្រាក់បញ្ញើ ដែលអតិថិជនអាចដាក់សន្សំបាន និងការធ្វើប្រតិបត្តិការហិរញ្ញវត្ថុផ្សេងលើគណនី គឺអាស្រ័យលើប្រភេទអតិថិជនជា Partial KYC ឬ Full KYC។

6.6. លោក-លោកស្រីអាចយកគណនីនេះ ធ្វើជាគណនីប្រភព នៃគណនីបញ្ញើមានកាលកំណត់បាន។

6.7. លោក-លោកស្រីអាចស្នើសុំបិទគណនីនេះបាន ដោយត្រូវអញ្ជើញមកស្នើសុំបិទជាលាយលក្ខណ៍អក្សរនៅសាខាណាមួយរបស់ខេប៊ីប្រាសាក់។

7. ការស្នើសុំប័ណ្ណខេប៊ីប្រាសាក់

7.1. លោក-លោកស្រី ដែលប្រើប្រាស់គណនីប្រាក់បញ្ញើសន្សំ ប្រភេទ **គណនីឯកត្តជនផ្ទាល់ខ្លួន/Single Account"** ឬ គណនីរួម (លក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា/Anyone to Sign) អាចធ្វើការស្នើសុំប័ណ្ណខេប៊ីប្រាសាក់ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) បានដោយខ្លួនឯង នៅគ្រប់ពេលវេលា និងទីកន្លែង។

7.2. លោក-លោកស្រីអាចជ្រើសរើសការទទួលយកប័ណ្ណជា 02 ជម្រើស៖

- ទៅទទួលប័ណ្ណនៅតាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត (Pick up at Bank) ឬ
- ស្នើសុំធនាគារបញ្ជូនប័ណ្ណទៅទីតាំងអតិថិជន (Bank Delivery)។

8. ប័ណ្ណនិម្មិតវីសា (Visa Virtual Card)

8.1. លោក-លោកស្រី អាចធ្វើការបង្កើតប័ណ្ណនិម្មិតវីសា (Visa Virtual Card) តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានគ្រប់ពេល និងគ្រប់ទីកន្លែង ដើម្បីប្រើប្រាស់លើការទូទាត់ទំនិញ/សេវាកម្មតាមអនឡាញ (Online Payment)។

8.2. លោក-លោកស្រី ត្រូវគោរពតាម «លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណនិម្មិត» ដែលអាចស្វែងរកបាននៅពេលបង្កើតប័ណ្ណនិម្មិតវីសាតាមកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ វេបសាយត៍ផ្លូវការខេប៊ីប្រាសាក់ ឬ តាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតលោកអ្នក។

9. ម៉ោងប្រតិបត្តិការ

9.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បាន 24 ម៉ោង ជាប្រចាំថ្ងៃ (24/7) លើកលែងតែមានការផ្អាកជាបណ្តោះអាសន្នដោយមានការជូនដំណឹងពី ខេប៊ីប្រាសាក់។

9.2. ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងដល់ លោក-លោកស្រី ករណីមានការផ្អាកប្រតិបត្តិការដើម្បីជួសជុល ឬ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធ។

9.3. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ ឬ ពេលមានការចាំបាច់ណាមួយ។

10. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់

10.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជាមួយរូបិយប័ណ្ណចំនួន 02 (ពីរ) ប្រភេទ រួមមាន៖

- ប្រាក់រៀល (KHR) និង
- ប្រាក់ដុល្លារអាមេរិក (USD)។

10.2. រាល់ប្រតិបត្តិការឆ្លងរូបិយប័ណ្ណ អត្រាប្តូរប្រាក់ត្រូវយោងទៅតាមអត្រាប្តូរប្រាក់ជាក់ស្តែងរបស់ ខេប៊ីប្រាសាក់ នៅក្នុងថ្ងៃ និងម៉ោងនៃការធ្វើប្រតិបត្តិការ ឬ យោងតាមអត្រាប្តូរប្រាក់នៃធនាគារអ្នកទទួលផល ករណីផ្ទេរឆ្លងរូបិយប័ណ្ណទៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេង។

11. ទំហំកំណត់នៃប្រតិបត្តិការ និងកម្រៃសេវា

11.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបាននៅពេលណាដែលគណនីរបស់ លោក-លោកស្រី មានសមតុល្យគ្រប់គ្រាន់ និងត្រូវគោរពទៅតាមទំហំកំណត់ដោយខេប៊ីប្រាសាក់។

11.2. លោក-លោកស្រី យល់ព្រម បង់កម្រៃសេវាផ្សេងៗ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ព្រមទាំងយល់ព្រមឱ្យខេប៊ីប្រាសាក់ ទូទាត់កម្រៃសេវាដោយផ្ទាល់ចេញពីគណនីរបស់ លោក-លោកស្រី ដោយពុំចាំបាច់ធ្វើការជូនដំណឹងជាមុនឡើយ។

11.3. លោក-លោកស្រីអាចស្វែងរកព័ត៌មានស្តីអំពីកម្រៃសេវា និង/ឬ ទំហំកំណត់ក្នុងមួយប្រតិបត្តិការ និងក្នុងមួយថ្ងៃទៅតាមប្រភេទប្រតិបត្តិការនីមួយៗ នៅលើគេហទំព័រផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ គ្រប់សាខាខេប៊ីប្រាសាក់ និង/ឬ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

12. សារជូនដំណឹងស្តីពីប្រតិបត្តិការកើតឡើងក្នុងគណនី (Push Notification)

លោក-លោកស្រី នឹងទទួលបានសារជូនដំណឹងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (Push Notification) ស្តីអំពីការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ការភ្ជាប់គណនីបន្ថែម ការបើកគណនីបន្ថែម និងការធ្វើប្រតិបត្តិការហិរញ្ញវត្ថុ ដែលបានកើតឡើងនៅក្នុងគណនីរបស់លោក-លោកស្រី លើកលែងតែមានភាពរអាក់រអួលពីប្រព័ន្ធ។

13. លក្ខណៈពិសេសផ្សេងៗពីប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

13.1. រាល់ការបញ្ចូលលេខកូដសម្ងាត់ (PIN) ឬ លេខកូដ OTP ខុស 03 ដង នោះកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នឹងត្រូវបានបង្ខាំងដោយស្វ័យប្រវត្តិ។ លោក-លោកស្រី អាចទាក់ទងមក ខេប៊ីប្រាសាក់ តាមរយៈលេខ 023/086 999 911 ឬ អញ្ជើញមកសាខា ខេប៊ីប្រាសាក់ ណាមួយដើម្បីស្នើសុំដោះបង្ខាំង។

13.2. រាល់ការបញ្ចូលព័ត៌មាន ដើម្បីចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (Online Self-Registration) ឬ ការកំណត់លេខកូដសម្ងាត់ថ្មី (Self PIN Reset) ខុសចំនួន 03 ដង នោះមុខងារនៃការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មុខងារកំណត់លេខកូដសម្ងាត់ថ្មី (Self PIN Reset) នឹងត្រូវបានបង្ខាំងដោយស្វ័យប្រវត្តិ។ ករណីនេះ លោក-លោកស្រី អាចទាក់ទងមក ខេប៊ីប្រាសាក់ តាមរយៈលេខ 023/086 999 911 ឬ អញ្ជើញមកសាខា ខេប៊ីប្រាសាក់ណាមួយដើម្បីស្នើសុំដោះបង្ខាំង។

13.3. រាល់ការ **ផ្ទេរប្រាក់តាមលេខសម្ងាត់ (Cash-Code)** លោក-លោកស្រី នឹងទទួលបានលេខកូដសម្ងាត់ចំនួន 06 ខ្ទង់ ដើម្បីធ្វើការដកប្រាក់តាមរយៈម៉ាស៊ីនអេធីអឹម ឬ ម៉ាស៊ីនដាក់ប្រាក់ ឬ ម៉ាស៊ីនឆូតកាតខេប៊ីប្រាសាក់ ក្នុងរយៈពេល 48 ម៉ោង។ ករណីហួសរយៈពេល 48 ម៉ោង ទឹកប្រាក់ផ្ទេរនឹងបង្វិលចូលទៅក្នុងគណនីដើមរបស់លោក-លោកស្រីវិញដោយស្វ័យប្រវត្តិ។

14. ការស្នើសុំបង្ខាំង ឬ ដោះបង្ខាំងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

14.1. លោក-លោកស្រី អាចស្នើសុំបង្ខាំង (Block) កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល តាមរយៈទូរស័ព្ទមកមន្ត្រីបម្រើសេវាអតិថិជន (023/086 999 911) ឬ អញ្ជើញមកកាន់សាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

14.2. ករណីស្នើសុំដោះបង្ខាំង (Unblock) កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឡើងវិញ លោក-លោកស្រី ត្រូវអញ្ជើញមកស្នើសុំជាលាយលក្ខណ៍អក្សរនៅសាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតបំផុត។

15. ការបញ្ឈប់ការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

លោក-លោកស្រី អាចស្នើសុំបញ្ឈប់ការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជាលាយលក្ខណ៍អក្សរបាន ដោយត្រូវអញ្ជើញទៅកាន់សាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតបំផុត។

16. សុវត្ថិភាពលើការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

16.1. សុវត្ថិភាពលើទូរស័ព្ទ

16.1.1. សូមកំណត់លេខសម្ងាត់ (Password) ឬ កំណត់ការស្កេនស្នាមខ្ចៅដៃ/ផ្ទៃមុខ (Fingerprint / Facial Recognition) ដើម្បីការពារទូរស័ព្ទដៃ របស់លោក-លោកស្រី ពីការចូលមើល ឬ ប្រើប្រាស់ពីបុគ្គលផ្សេងដោយគ្មានការអនុញ្ញាត។

16.1.2. មិនត្រូវផ្តល់ ឬ បង្ហាញ **លេខសម្ងាត់** (Password) ឬ អនុញ្ញាតឱ្យបុគ្គលណាម្នាក់ធ្វើការកំណត់ **លេខសម្ងាត់ ឬ ស្កេនស្នាមខ្ចៅដៃ / ផ្ទៃមុខ** ឬ ចូលប្រើប្រាស់ទូរស័ព្ទដៃ ជំនួស លោក-លោកស្រី ជាដាច់ខាត បើទោះបីជាបុគ្គលនោះជា អ្នករួមគណនី ឬ សាច់ញាតិ ឬ មិត្តភក្តិ ឬ បុគ្គលិកខេប៊ីប្រាសាក់ ក៏ដោយ។ល។

16.1.3. មិនត្រូវកត់ត្រាលេខសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងទូរស័ព្ទជាដាច់ខាត។

16.1.4. ត្រូវប្រាកដថារាល់ការបញ្ចូល **លេខសម្ងាត់** (Password) ដើម្បីចូលប្រើប្រាស់ទូរស័ព្ទដៃ របស់លោក-លោកស្រី មិនត្រូវបានលួចមើល ឬ ដឹងដោយបុគ្គលណាម្នាក់ឡើយ។

16.1.5. ត្រូវធ្វើការផ្លាស់ប្តូរ **លេខសម្ងាត់** (Password) ទូរស័ព្ទដៃ របស់លោក-លោកស្រី ឱ្យបានញឹកញាប់ ឬ ករណីសង្ស័យថាលេខសម្ងាត់ត្រូវបានដឹងដោយបុគ្គលណាម្នាក់។

16.1.6. សូមកុំប្រើទូរស័ព្ទដៃ ដែលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ទៅភ្ជាប់ជាមួយសេវាអ៊ីនធឺណែតសាធារណៈ ឬ ប្រើរួមជាមួយអ្នកដទៃ ដើម្បីចៀសវាងពីការបន្លំលួចដោយ Hacker។

16.1.7. មិនត្រូវភ្ជាប់ប្រព័ន្ធ ឬ បញ្ចូលកម្មវិធី ដែលមិនស្គាល់ក្នុងទូរស័ព្ទ ឡើយ។ ករណីបានភ្ជាប់ ត្រូវផ្តាច់ ឬ លុបចេញ និងសម្អាតភ្លាមៗ ដើម្បីចៀសវាងការឆ្លងមេរោគ ឬ ការបន្លំលួចប្រាក់របស់លោក-លោកស្រី (Virus and/or Hacker)។

16.1.8. ត្រូវដំឡើងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និងធ្វើបច្ចុប្បន្នភាពលើកម្មវិធីទូរស័ព្ទ ដោយផ្ទាល់ពី Play Store ឬ App Store។

16.1.9. សូមកុំទុកទូរស័ព្ទដៃ ដែលកំពុងបើកកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ចោលនៅទីសាធារណៈ និងត្រូវ **ចាក់សោទូរស័ព្ទ** (Lock Phone) ភ្លាមៗករណីឈប់ប្រើប្រាស់។

16.1.10. សូមចាកចេញ (Logout) ឬ លុបប្រតិបត្តិការ (Clear History) និងបិទកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នៅពេល លោក-លោកស្រីធ្វើប្រតិបត្តិការរួចរាល់។

16.1.11. ករណីលោក-លោកស្រី លក់ ឬ ជួសជុល ឬ ផ្ទេរទូរស័ព្ទ ឬ កុំព្យូទ័រ ឱ្យអ្នកផ្សេង ត្រូវលុបកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ ព័ត៌មានពាក់ព័ន្ធផ្សេងៗចេញពីក្នុងទូរស័ព្ទដៃ ឱ្យបានរួចរាល់ជាមុន។

16.1.12. ករណីបាត់ទូរស័ព្ទ ឬ សង្ស័យមានអ្នកផ្សេងស្គាល់លេខសម្ងាត់ចូលប្រើប្រាស់ទូរស័ព្ទដៃ ត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ជាបន្ទាន់តាមរយៈលេខ 023/086 999 911 ដើម្បីបង្ខាំងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ ចាត់វិធានការផ្សេងៗតាមលក្ខណៈបច្ចេកទេស ដើម្បីទប់ស្កាត់ការបន្លំធ្វើប្រតិបត្តិការ។

16.2. សុវត្ថិភាពលើលេខកូដសម្ងាត់ ឬ លេខកូដ OTP និងព័ត៌មានពាក់ព័ន្ធ

16.2.1. សូមចងចាំលេខកូដសម្ងាត់ (PIN) របស់លោក-លោកស្រី ហើយកុំកត់ត្រាលើអ្វីមួយ ឬ ឱ្យអ្នកដទៃដឹង។

16.2.2. សូមរក្សាលេខកូដសម្ងាត់ (PIN) ឬ លេខកូដ OTP និងព័ត៌មានផ្សេងៗរបស់លោក-លោកស្រីឱ្យមានសុវត្ថិភាព។ រាល់ការខូចខាតដែលកើតចេញពីការធ្វេសប្រហែសក្នុងការរក្សាព័ត៌មានសម្ងាត់ខាងលើ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

16.2.3. សូមកុំផ្តល់ ឬ ផ្ញើលេខកូដសម្ងាត់(PIN) ឬ លេខកូដ OTP ឬ ព័ត៌មានផ្ទាល់ខ្លួនដល់នរណាម្នាក់ឡើយ ទោះដោយផ្ទាល់មាត់ ឬ តាមរយៈការផ្ញើសារអេឡិចត្រូនិកអាចជា អ៊ីម៉ែល Facebook Messenger ឬ តេឡេក្រាម (Telegram)... ជាដើម។

16.2.4. សូមកុំប្រើ ថ្ងៃខែឆ្នាំកំណើត ឬ លេខទូរស័ព្ទ ឬ លេខគណនី ឬ លេខអត្តសញ្ញាណប័ណ្ណ ឬ លេខរៀងដែលងាយស្រួលចាំ ឬ ស្រួលស្មានដឹង (ឧ. 111111 ឬ 123456...) មកធ្វើជា លេខកូដសម្ងាត់ (PIN) ដើម្បីចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

16.2.5. ប្រសិនបើមានការកត់សម្គាល់ណាមួយដែលបង្ហាញថា ស្រោមសំបុត្រលេខកូដសម្ងាត់របស់លោក-លោកស្រីត្រូវគេហែកមើលនោះ សូមទាក់ទងមកសាខាខេប៊ីប្រាសាក់ ដែលនៅជិតលោក-លោកស្រីជាបន្ទាន់។

16.2.6. លោក-លោកស្រី ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លេខទូរស័ព្ទ ឬ អាសយដ្ឋាន Email ដែលបានបោះពុម្ពលើសារសម្ងាត់ PIN Mailer នៅពេលទទួលបានពីបុគ្គលិកខេប៊ីប្រាសាក់។

16.2.7. ត្រូវធានាឱ្យច្បាស់ថា រាល់ពេល លោក-លោកស្រី បញ្ចូលលេខកូដសម្ងាត់ (PIN) ដើម្បីចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល មិនត្រូវបានអ្នកដទៃឃ្លាំមើល ឬ ក៏មានមនុស្សនៅក្បែរអ្នកឡើយ។

16.2.8. សូមធ្វើការផ្លាស់ប្តូរលេខកូដសម្ងាត់ (PIN) ឱ្យបានញឹកញាប់ និង/ឬ ក្នុងករណីសង្ស័យថា លេខកូដសម្ងាត់ (PIN) ត្រូវបានដឹងដោយអ្នកដទៃ។

16.2.9. លោក-លោកស្រី គួរកំណត់លេខកូដសម្ងាត់ (PIN) ចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឱ្យខុសពី លេខសម្ងាត់ (Password) បើកសោទូរស័ព្ទដៃរបស់ខ្លួន។

16.2.10. ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាបន្ទាន់ប្រសិនបើ លោក-លោកស្រី ភ្លេចលេខកូដសម្ងាត់ (PIN) ឬ សង្ស័យអ្នកផ្សេងបានដឹង។

16.3. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ

16.3.1. សូមប្រុងប្រយ័ត្នការបោកបញ្ឆោតយកព័ត៌មាន តាមរយៈទូរស័ព្ទ អ៊ីម៉ែល វេបសាយត៍ កម្មវិធីដែលលោតផ្ទាំងមក (pop-up window) ឬ សារ (SMS) ដែលជាល្បិច ឱ្យ លោក-លោកស្រី បញ្ចូលព័ត៌មានសំខាន់ៗ ដូចជា៖ លេខកូដសម្ងាត់ (PIN) ឬ លេខកូដ OTP ឬ លេខទូរស័ព្ទ (Phone) ឬ ថ្ងៃខែឆ្នាំកំណើត (Date of Birth) ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗជាដើម។ល។

16.3.2. ខេប៊ីប្រាសាក់ នឹងមិនស្នើសុំ លោក-លោកស្រី ឱ្យប្រាប់ពី លេខកូដសម្ងាត់ (PIN) និង/ឬ លេខកូដ OTP ដើម្បីចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាលឡើយ ទោះបីជាសុំដោយផ្ទាល់មាត់ តាមទូរស័ព្ទ អ៊ីម៉ែល ឬ តាមមធ្យោបាយទំនាក់ទំនងណាមួយ។

16.3.3. ប្រសិនបើ លោក-លោកស្រី ទទួលបានអ៊ីម៉ែល ឬ សារទូរស័ព្ទ ឬ ការហៅទូរស័ព្ទ ដែលស្នើសុំព័ត៌មានខាងលើ សូមលុបចោល ឬ បដិសេធជាបន្ទាន់ និង/ឬ មិនត្រូវចុចលើតំណភ្ជាប់បណ្តាញ (Link) ឬ បើកឯកសារភ្ជាប់ណាមួយដែលមាននៅក្នុងអ៊ីម៉ែលនោះឡើយ។

16.3.4. ប្រសិនបើ លោក-លោកស្រី មានចម្ងល់ ឬ ក៏មានមន្ទិលសង្ស័យលើវេបសាយត៍ ឬ អ៊ីម៉ែលណាមួយ សូមទាក់ទងមកយើងខ្ញុំតាមរយៈ info@kbprasacbank.com.kh ឬ ទូរស័ព្ទលេខ 023/086 999 911។

17. សិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជន

17.1. លោក-លោកស្រី ត្រូវធានាថាគ្រប់ព័ត៌មានដែលបានផ្តល់មក ខេប៊ីប្រាសាក់ ជាព័ត៌មានត្រឹមត្រូវ និង ថ្មីបំផុត។ ករណី លោក-លោកស្រី ផ្តល់ព័ត៌មានមិនពិត ឬ ក្លែងក្លាយ នោះ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

17.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យកម្រៃសេវា និងព័ត៌មាននៃការទូទាត់ឱ្យបានត្រឹមត្រូវមុននឹងបញ្ជាការទូទាត់នៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ រាល់ការបញ្ចូលព័ត៌មាន ឬ លេខគណនីខុស ឬ ផ្ទេរសមតុល្យលើស ឬ ខ្វះ ជាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

17.3. លោក-លោកស្រី ត្រូវទទួលខុសត្រូវលើការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ រាល់ការបាត់បង់ទឹកប្រាក់ក្នុងគណនីផ្ទាល់ខ្លួន ឬ គណនីរបស់អ្នកផ្សេង ដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ឬ ដោយការធ្វេសប្រហែស ឬ ដោយការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬ ដោយប្រយោលតែម្នាក់ឯង ឬ ដោយមានការចូលរួមពីអ្នកដទៃ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

17.4. លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌក្នុងការទូទាត់សំណងមក ខេប៊ីប្រាសាក់ ករណីមានការប្តឹងតវ៉ា ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ឬ ការចំណាយផ្សេងៗ ដែលខេប៊ីប្រាសាក់ទទួលរងទាក់ទងនឹងប្រតិបត្តិការតាមកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដោយការអនុវត្តបំពានរបស់ លោក-លោកស្រី លើលក្ខខណ្ឌនៃការប្រើប្រាស់សេវាកម្មនេះ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការក្លែងបន្លំ។ល។

17.5. លោក-លោកស្រី ត្រូវធានាពីការរក្សាសុវត្ថិភាពទូរស័ព្ទ និងព័ត៌មានសម្ងាត់ ដើម្បីចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដូចជាលេខកូដសម្ងាត់ និងព័ត៌មានផ្ទាល់ខ្លួន។ល។

17.6. លោក-លោកស្រី ត្រូវធានាថាបានដំឡើង ឬ ធ្វើបច្ចុប្បន្នភាព **កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល** (KB PRASAC Mobile Application) ដោយផ្ទាល់ពី Play Store ឬ App Store និងធានាថាបានប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជំនាន់ថ្មីបំផុត ដែលបានដាក់ឱ្យប្រើប្រាស់ ឬ ធ្វើបច្ចុប្បន្នភាពពីខេប៊ីប្រាសាក់។

17.7. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាលាយលក្ខណ៍អក្សរឱ្យបានទាន់ពេលវេលា ក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទ អ៊ីម៉ែល និង/ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗ ដែលបានផ្តល់មក ខេប៊ីប្រាសាក់។ រាល់ការខាតបង់ ឬ ការពន្យារពេលផ្សេងៗដែលអាចកើតមកពីការខកខានមិនបានជូនដំណឹងមក ខេប៊ីប្រាសាក់ ជាការទទួលខុសត្រូវទាំងស្រុងរបស់ លោក-លោកស្រី។

17.8. លោក-លោកស្រី មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលខុសច្បាប់ ឬ សកម្មភាពអាជីវកម្មណាមួយ ដែលត្រូវបានហាមឃាត់តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឡើយ។

17.9. លោក-លោកស្រី មានសិទ្ធិក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងរបាយការណ៍គណនីរបស់ខ្លួន និងសាកសួរមក ខេប៊ីប្រាសាក់ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។

17.10. ក្នុងករណី លោក-លោកស្រី មានបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល លោក-លោកស្រី ត្រូវជូនដំណឹងជាបន្ទាន់មក ខេប៊ីប្រាសាក់ តាមរយៈទូរស័ព្ទ 023/086 999 911។

17.11. លោក-លោកស្រី ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគ្រប់ចំណុចនៅលើ «**លក្ខខណ្ឌនៃការប្រើប្រាស់ខេប៊ីប្រាសាក់ម៉ូបាល**» នេះ។

18. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

18.1. ខេប៊ីប្រាសាក់ មានសិទ្ធិផ្ទៀងផ្ទាត់ព័ត៌មានរបស់ លោក-លោកស្រី និងសម្រេចក្នុងការផ្តល់ជូននូវសេវាខេប៊ីប្រាសាក់ម៉ូបាលដល់ លោក-លោកស្រី។

18.2. ខេប៊ីប្រាសាក់ នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការទូទាត់តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលរបស់លោក-លោកស្រី ប៉ុន្តែខេប៊ីប្រាសាក់ មិនទទួលខុសត្រូវ ក្នុងករណីដែល លោក-លោកស្រី បានបញ្ចូលព័ត៌មាន ឬ លេខគណនីខុស ឬ ផ្ទេរសមតុល្យលើស ឬ ខ្វះ ជាដើម។

18.3. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល របស់ លោក-លោកស្រី ដោយយោងលើច្បាប់/បទបញ្ញត្តិ ឬ ដីកាពីតុលាការ។

18.4. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់ លោក-លោកស្រី លើកលែងតែមានការយល់ព្រមពី លោក-លោកស្រី ឬ ច្បាប់តម្រូវ ឬ មានដីកាពីតុលាការបង្គាប់ឱ្យបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ។

18.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ ឬ អនុវត្តការយកកម្រៃសេវាប្រចាំឆ្នាំ/ប្រចាំខែ និង/ឬ កម្រៃសេវាពាក់ព័ន្ធលើការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល អាស្រ័យលើលក្ខខណ្ឌ និងស្ថានភាពអាជីវកម្មជាក់ស្តែង។

18.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ទៅជំនាន់ថ្មីៗ ដោយ ខេប៊ីប្រាសាក់ អាចនឹង៖

- ដាក់បន្ថែមនូវមុខងារប្រតិបត្តិការថ្មីៗ ដោយយោងទៅតាមនិន្នាការទីផ្សារ និង/ឬ ការប្រែប្រួលបច្ចេកវិទ្យា ឬ
- លុប ឬ ផ្អាកជាបណ្តោះអាសន្នលើមុខងារណាមួយ ប្រសិនបើមានបញ្ហាបច្ចេកទេសណាមួយកើតឡើង ដែលអាចមានផលប៉ះពាល់ដល់ប្រព័ន្ធធនាគារ ឬ ក្នុងគោលបំណងថែទាំប្រព័ន្ធ ឬ ផ្សេងៗ។

18.7. នៅក្នុងដំណាក់កាលណាមួយ ខេប៊ីប្រាសាក់ អាចនឹងជំរុញឱ្យ លោក-លោកស្រី ធ្វើបច្ចុប្បន្នភាពកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល មកជំនាន់ថ្មីចុងក្រោយបង្អស់ (Update Last Version) ដើម្បីបង្កើនសុវត្ថិភាព និងភាពដូចគ្នាលើការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

18.8. ប្រសិនបើ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល របស់លោក-លោកស្រី មិនអាចប្រើប្រាស់បានដោយករណីប្រធានសក្តិ ខេប៊ីប្រាសាក់ នឹងជួយដល់ លោក-លោកស្រី ក្នុងការរកដំណោះស្រាយ ឬ ផ្តល់ជំនួយការចាំបាច់ណាមួយ យោងលើហេតុផលជាក់ស្តែង ប៉ុន្តែខេប៊ីប្រាសាក់មិនទទួលខុសត្រូវទៅលើហេតុការណ៍ទាំងនោះទេ។

18.9. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ និងពេលមានការចាំបាច់ជាដើម។

18.10. ខេប៊ីប្រាសាក់ ផ្តល់លេខទូរស័ព្ទសម្រាប់បម្រើសេវាប្រឹក្សាអំពីសេវាកម្ម និងការរាយការណ៍ពីការភ្លេចលេខសម្ងាត់ ឬ បញ្ហាផ្សេងៗដែលកើតមាន តាមរយៈលេខ 023/086 999 911។

19. ការកែប្រែកម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង

19.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែកម្រៃសេវា ទំហំកំណត់ និង/ឬ លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល របស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅអតិថិជនឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

19.2. ក្នុងរយៈពេលនៃការជូនដំណឹងខាងលើ ករណីមិនមានការតវ៉ាពី លោក-លោកស្រី ត្រូវសន្មតថា លោក-លោកស្រីបានយល់ព្រម និងទទួលយកការកែប្រែទាំងនោះមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1). សាខាខេប៊ីប្រាសាក់ និង/ឬ
2). វេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ
3). ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី
4). ការផ្សព្វផ្សាយនៅលើទំព័រការសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មធ្យោបាយផ្សេងៗ ដែល ខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

19.3. អតិថិជនត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួនតាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

20. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូន លោក-លោកស្រី ប្រសិនបើ ខេប៊ីប្រាសាក់ មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

1). ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់បញ្ញើនោះ

2). ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ

3). មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។ល។

21. ច្បាប់ និងការដោះស្រាយវិវាទ

21.1. លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

21.2. ករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធី។ ករណីវិវាទមិនអាចដោះស្រាយបានដោយសន្តិវិធី ឬ ក្រៅប្រព័ន្ធតុលាការ នោះវិវាទត្រូវដោះស្រាយទៅតាមប្រព័ន្ធតុលាការដោយយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

21.3. លក្ខខណ្ឌផ្សេងៗដែលមិនមានចែងនៅក្នុង «**លក្ខខណ្ឌប្រើប្រាស់**» នេះ ត្រូវអនុវត្តតាមគោលនយោបាយរបស់ខេប៊ីប្រាសាក់ និង/ឬ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

22. ស្វ័យភាព នៃបញ្ញត្តិ

ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌប្រើប្រាស់នេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃលក្ខខណ្ឌប្រើប្រាស់នេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

23. ភាសា

លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសារខ្មែរចាត់ទុកជាផ្លូវការ៕